IHSS
IN-HOME SUPPORTIVE SERVICES

CDSS

# ការកំណត់ និងការប្រកាន់ខ្ជាប់កម្រិតព្រំដែន

ផ្នែកមួយនៃការងាររបស់អ្នកជានិយោជកគឺដើម្បីកំណត់ការរំពឹងទុកសម្រាប់អ្នកផ្តល់សេវារបស់អ្នក។

## លក្ខខ័ណ្ឌលើកិច្ចការ និងម៉ោង

- មិនត្រូវឱ្យអ្នកផ្តល់សេវារបស់អ្នកធ្វើកិច្ចការ ឬម៉ោងធ្វើការដែលមិនត្រូវបានអនុញ្ញាត។ កម្មវិធី IHSS នឹងមិនបង់ប្រាក់សំរាប់កិច្ចការដែលគ្មានការអនុញ្ញាត ឬម៉ោងបន្ថែមទេ។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងកិច្ចការដែលមិនត្រូវបានរ៉ាប់រងដោយកម្មវិធី IHSS ដូចជា ការថែរក្សាសត្វចិញ្ចឹម ជំនួយជាមួយនឹងការយកសំបុត្រ ឬហិរញ្ញវត្ថុ ឬការតាមជូនទៅក្នុងសកម្មភាពសង្គម អ្នកប្រហែលជាចង់សុំសមាជិកគ្រួសារ និងមិត្តភក្តិឱ្យជួយអ្នកក្នុងកិច្ចការទាំងនោះ។ ប្រសិនបើអ្នកសំរេចចិត្តថានឹងជួលអ្នកផ្តល់សេវា IHSS របស់អ្នកអោយធ្វើការឱ្យអ្នក ដើម្បីផ្តល់ជំនួយជាមួយនឹងកិច្ចការដែលមិនមែនជាសេវាការមើលថែទាំក្នុងផ្ទះ (non-IHSS) វាគឺជាការទទួលខុសត្រូវរបស់អ្នក និងអ្នកផ្តល់សេវារបស់អ្នកក្នុងការព្រមព្រៀងគ្នាលើការងារ និង/ឬ ការរៀបចំការបង់ប្រាក់សំរាប់ជំនួយជាមួយសេវាកម្ម IHSS ដែលមិនត្រូវបានបង់ប្រាក់ឱ្យ។
- បង្ហាញឥរិយាបថថាជាអ្នកមានវិជ្ជាជីវ: នៅពេលដែលកន្លែងធ្វើការងារ ជាផ្ទះ។
- អ្នកផ្តល់សេវារបស់អ្នកមិនគួរនាំកូនក្មេង ឬអ្នកផ្សេងទៀតមកផ្ទះរបស់អ្នកទេ។ ផ្ទះរបស់អ្នកគឺជាកន្លែងធ្វើការ ហើយការងាររបស់គាត់គឺដើម្បីផ្តល់សេវា IHSS សំរាប់អ្នក។
- អ្នកផ្តល់សេវារបស់អ្នកមិនគួរចំណាយពេលរបស់គាត់មកជជែកលេងជាមួយអ្នក ជាជាងធ្វើការងារទេ។ អ្នកផ្តល់សេវារបស់អ្នកអាចត្រូវរំលឹកដោយការគួរសម ដើម្បីបន្តធ្វើការងារ។
- គាត់គួរតែនាំយកអាហារថ្ងៃត្រង់ ឬអាហារពេលល្ងាចមកដោយខ្លួនឯង ប្រសិនបើធ្វើការនៅម៉ោងបាយ។
- គាត់មិនគួរប្រើប្រាស់ទ្រព្យសម្បត្តិ ឬរបស់របររបស់អ្នកសម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់គាត់ឡើយ។

## ការពារសិទ្ធិជាឯកជនរបស់អ្នក

- អ្នកផ្តល់សេវារបស់អ្នកមិនគួរផ្តល់ព័ត៌មាននៃឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ ស្ថានភាពសុខភាព ស្ថានភាពគ្រួសារ ឬអាកប្បកិរិយារបស់អ្នកជាមួយមនុស្សដែលគ្មានការអនុញ្ញាតឡើយ។
- វាគឺជាការសំខាន់សំរាប់អ្នកផ្តល់សេវារបស់អ្នកដើម្បីដឹងអំពីស្ថានភាពសុខភាពរបស់អ្នក និងទំនាក់ទំនងគ្រួសារក្នុងករណីពេលមានអាសន្ន។ ទោះយ៉ាងណាក៏ដោយ សូមរក្សាព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតជាឯកជន។
- អ្នកផ្តល់សេវារបស់អ្នកមិនគួរមានសិទ្ធិចូលប្រើសៀវភៅមូលប្បទានប័ត្រ គណនីធនាគារ ប័ណ្ណឥណទាន ព័ត៌មានហិរញ្ញវត្ថុ ឬប្រាក់ដែលរក្សាទុកនៅក្នុងផ្ទះរបស់អ្នកទេ។
- អ្នកគួរតែទុកដាក់ការពាររបស់មានតម្លៃណាមួយនៅកន្លែងដែលមានសុវត្ថិភាព ហើយមិនត្រូវប្រាប់អ្នកផ្តល់សេវារបស់អ្នកពីកន្លែងដែលពួកវាត្រូវបានរក្សាទុកឡើយ។

IHSS
IN-HOME SUPPORTIVE SERVICES

CDSS

## អ្វីដែលត្រូវជៀសវាង

- ✓ មិនត្រូវឱ្យអ្នកផ្តល់សេវារបស់អ្នកចុះហត្ថលេខាលើឈ្មោះរបស់អ្នកគ្រប់ពេល។
- ✓ មិនត្រូវយល់ព្រមលើទំព័រកត់ត្រាពេលម៉ោងធ្វើការដែលមិនត្រឹមត្រូវ។
- ✓ មិនត្រូវផ្តល់ព័ត៌មាននៃធនាគាររបស់អ្នកជាមួយអ្នកផ្តល់សេវារបស់អ្នក ហើយមិនត្រូវបន្ថែមឈ្មោះរបស់ពួកគេទៅក្នុងគណនីសន្សំ គណនីមូលប្បទានប័ត្រ ឬគណនីកាតឥណទានរបស់អ្នក។
- ✓ មិនត្រូវផ្តល់លេខសូស្យាល់សឹគ្យូរីទីរបស់អ្នក។
- ✓ មិនត្រូវភ្លេចប្រមូលឬទាររក និងពិនិត្យបង្កាន់ដៃរបស់អ្នក ប្រសិនបើ អ្នកផ្តល់ប្រាក់ដល់អ្នកផ្តល់សេវារបស់អ្នក ដើម្បីទិញអ្វីមួយសំរាប់អ្នក។
- ✓ មិនត្រូវទុកវត្ថុមានតម្លៃ ឬឯកសារសំខាន់ៗនៅក្នុងទីតាំងដែលអាចមើលឃើញ។
- ✓ មិនត្រូវឱ្យគាត់ខ្ចីលុយ យានជំនិះ ឬរបស់របរផ្ទាល់ខ្លួន។
- ✓ មិនត្រូវចូលរួមក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នកផ្តល់សេវារបស់អ្នក។

**សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យខោនធីផ្នែក IHSS ក្នុងតំបន់របស់អ្នក។**